ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទ

## រយៈពេល ៣ ឆ្នាំ

## (២០០៨-២០១០)

ឈ្មោះសហគមន៍នេសាទ : គរថ្មី

ភូមិ : គរថ្មី

ឃុំ : កោះថ្កូវ

ស្រុក : ជលគីរី

ខេត្ត : កំពង់ឆ្នាំង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទ

## រយៈពេល ៣ ឆ្នាំ

## (២០០៨-២០១០)

ឈ្មោះសហគមន៍នេសាទ : គរថ្មី

ភូមិ : គរថ្មី

ឃុំ : កោះថ្កូវ

ស្រុក : ជលគីរី

ខេត្ត : កំពង់ឆ្នាំង

# ផែនការគ្រប់គ្រង

# កន្លែងនេសាទសហគមន៍

## ១ ស្ថានភាពទូទៅ

សហគមន៍នេសាទគរជ្រុំត្រូវបានបង្កើតឡើងដោយមហាសន្និបាតកំណើតដំបូងនៅថ្ងៃទី **២០** ខែ **កក្កដា** ឆ្នាំ **២០០៧** និងបានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ចុះថ្ងៃទី **១១** ខែ **មករា** ឆ្នាំ **២០០៨**។

សហគមន៍នេសាទ **គរជ្រុំ** មានទីតាំងស្ថិតនៅក្នុងភូមិ **គរជ្រុំ** ឃុំ **កោះថ្កូវ** ស្រុក **ជលគិរី** ខេត្ត **កំពង់ឆ្នាំង** ដែលមានសមាជិកសរុបចំនួន **៣៦៥** នាក់ ស្រីចំនួន **១៨៨** នាក់ និងមានគណៈកម្មការចំនួន **១១** នាក់ ស្រីចំនួន **១** នាក់។ ក្នុងនោះចំនួនគ្រួសារសរុប មានចំនួន **២២៦** គួសារ ។

កន្លងមកសហគមន៍នេសាទនេះបានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួន រួមមាន: បង្ក្រាបបទល្មើសនេសាទ ដាំព្រៃលិចទឹកនៅមាត់បឹងភក់ ១៤០០ ដើម ស្មើ ៥.៥ ហិកតា ចុះល្បាត ជួយកសាងសាលាបុណ្យ ស្ពារព្រែកថ្មី ជួសជុលទំនប់ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងធ្វើផែនទី។

## ២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក -ប្រជាពលរដ្ឋ:

- ចំនួនប្រជាពលរដ្ឋសរុបក្នុងសហគមន៍នេសាទមាន **១១៤៤** នាក់ ប្រុស **៥៧៥** នាក់ ស្រី **៥៦៩** នាក់ **២២៣** គ្រួសារក្នុងនោះមានជនជាតិខ្មែរចំនួន **១១៤៤** នាក់ ខ្មែរឥស្លាម និងអាណិកជនវៀតណាម **គ្មាន**។
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន ១២ នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន ១៦ នាក់ ស្រី ៧ នាក់ ប្រុស ៩ នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ១១ នាក់ ស្រី ៥ នាក់
- កុមារកំព្រាក្នុងសហគមន៍នេសាទមាន ២៨ នាក់ ស្រី ១៧
- ចំនួនអ្នកមានជំងឺរ៉ាំរ៉ៃក្នុងសហគមន៍នេសាទ មាន ៤ នាក់ ប្រុស ១ នាក់
- ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធ **១០០ %**។ ក្រៅពីនេះគ្មានអ្នកកាន់សាសនាអ៊ីស្លាម និងសាសនាកាតូលិកទេ
- ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់អ្នកមិនចេះអក្សរមានចំនួន **៩៥** នាក់ ស្រី **១៨** នាក់ កំរិតថ្នាក់បឋមសិក្សាចំនួន **៣០០** នាក់ ស្រី **១៨០** នាក់ កំរិតមធ្យមសិក្សាចំនួន ៤០ នាក់ ស្រី **១២** នាក់ និងកំរិតថ្នាក់ឧត្តមសិក្សា **១** នាក់ ប្រុស **១** នាក់។

### ខ -មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមាន:

- ធ្វើនេសាទចំនួន ២២០ គ្រួសារ
- ធ្វើស្រែប្រាំងចំនួន ២២៣ គ្រួសារ ទំហំ ២២០ ហិកតា ( ប្រាំង )
- ដាំបន្លែចំនួន ២២៣ គ្រួសារ មានផ្ទៃដីទំហំ ២ ហិកតា
- ជាងផ្ទះចំនួន ២ គ្រួសារ ជាងទូក ៤ គ្រួសារ
- ធ្វើចំការចំនួន ២២៣ គ្រួសារ មានផ្ទៃដីទំហំ ១១០ ហិកតា
- អ្នកលក់ដូរក្នុងភូមិចំនួន ២០ គ្រួសារ ( លក់ចាប់ហួយ)
- កែច្នៃផលនេសាទ ១៨០ គ្រួសារសម្រាប់ផ្គត់ផ្គង់ក្នុងគ្រួសារ
- ធ្វើវារីវប្បកម្ម ៣ គ្រួសារ ទំហំស្រះ ២០ម x ២០ម x ០.៣ម
- ជួលធុងបាស ២ គ្រួសារ
- ជួលរោងការ ២ គ្រួសារ
- រត់ទូកដរ ១ គ្រួសារ

## ៣. កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍

### ក. ទីតាំង

កន្លែងនេសាទសហគមន៍ **គរជ្រុំ** ស្ថិតនៅក្នុងអតីតឡូត៍នេសាទលេខ **១៥** នៃដែននេសាទទឹកសាប ។ កន្លែងនេសាទសហគមន៍ **គរជ្រុំ** ដែលមានទំហំ **៩៥៤** ហិកតា និងមានកំណត់និយាមកា ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង ។

មានព្រំប្រទល់ :

- ខាងជើងទល់នឹង **សហគមន៍កំពង់ខ្លាញ់**
- ខាងត្បូងទល់នឹង **សហគមន៍កោះស្នែង**
- ខាងកើតទល់នឹង **សហគមន៍បត់ត្រង់**
- ខាងលិចទល់នឹង **ទន្លេគជ្រុំ**

### ខ. ដែននេសាទ

កន្លែងនេសាទសហគមន៍ **គរជ្រុំ** មានបឹងចំនួន **៥** ព្រែកចំនួន **១** ប្រឡាយចំនួន **១** ត្រពាំងចំនួន **២** គ្មានបៀ និងមេទឹក **គ្មាន** ។

- បឹងឈ្មោះ **កន្លែងចក** ទំហំ ៩០ ហិកតា នេសាទ ពេញ ១ឆ្នាំ
- បឹងឈ្មោះ **ដូនវល្លិ** ទំហំ ២៧. ៥ ហិកតា នេសាទ ពេញ ១ឆ្នាំ
- បឹងឈ្មោះ **បឹងភក់** ទំហំ ៩ ហិកតា អភិរក្ស
- បឹងឈ្មោះ **បឹងវង្វេង** ទំហំ ៩ ហិកតា នេសាទ ពេញ ១ឆ្នាំ

- បឹងឈ្មោះ **អន្លង់រាំង** ទំហំ ៦ ហិកតា នៅសាទ ពេញ ១ឆ្នាំ
- ព្រែកឈ្មោះ **ព្រែកថ្មី** ប្រវែង ៣០០ម នៅសាទពីខែ វិច្ឆកា ដល់ខែ កុម្ភៈ
- ត្រពាំងឈ្មោះ **អន្លង់រាំង** ទំហំ ៧៥០០ ម$^{២}$ នៅសាទពីខែ វិច្ឆកា ដល់ខែ កុម្ភៈ
- ត្រពាំងឈ្មោះ **ដីថ្មី** ទំហំ ៥០ ហិកតា នៅសាទ ពេញ ១ ឆ្នាំ
- ស្រះឈ្មោះ **តាសុវណ្ណ** ទំហំ ៤០០ ម$^{២}$
- ព្រៃលិចទឹកឈ្មោះ **មៀន** ទំហំសរុប ២០៦ ហិកតា
- ព្រៃឈ្មោះ **ខ្នងទួលឆកឫស្សី** ទំហំ ៦០ ហិកតា
- ព្រៃឈ្មោះ **ចុងប្រាំង** ទំហំ ៥០ ហិកតា
- ព្រៃឈ្មោះ **បឹងភក់** ទំហំ ៨០ ហិកតា
- ដីទំនាបលិចទឹកមានទំហំសរុប **៩៥៤** ហិកតា

**គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស**

- បឹងឈ្មោះ **បឹងភក់** ទំហំ **៩** ហិកតា

**ឃ. ធនធានផលផល**

**ឃ.១ ប្រភេទត្រី :**

ឃ.១.១ ប្រភេទត្រីកើនឡើង

រស់,ក្រាញ់,កន្ទ្រប់,ឆ្ពោរ,ដំរី,អណ្តែង,ប្រា,ឆ្ពិន,ពោ,ឆ្លាំង,កញ្ចុះ,ច្រឡឹង,ក្អែក,ជន្ទាស់ភ្លុក,បណ្តូលអំពៅ,ចង្វារ ។

ឃ.១.២ ប្រភេទត្រីថយចុះ

ព្រួល,គល់រាំង,ខ្យា,ព្រលូង,ក្រាយ,ក្បក,ប្រម៉ា ។

ឃ.១.៣ ប្រភេទត្រីដដែល

រៀល,លិញ .ប្រម៉ា,កាហែ,ក្អែក,ឆ្កោក,ក្អុក,អណ្តាតឆ្កែ,ព្រលូង,ឆ្ពិន,ឆ្លាំង, ។

**ឃ.២ ប្រភេទវារីសត្វ**

ឃ.២.១ ប្រភេទវារីសត្វកើន

គ្មាន

ឃ.២.២ ប្រភេទវារីសត្វថយចុះ

អណ្តើក,កន្ធាយ,ពស់,ភេ,អន្សង,ត្រគួត ។

ឃ.២.៣ ប្រភេទវារីសត្វដដែល

ពស់ទឹក,ក្តាម,ខ្យង

### ឃ.៣ ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ

ឃ.៣.១ ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិកើន

គ្មាន

ឃ.៣.២ ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិថយចុះ

រាំង,ញ,ចង្កែង,រញ្ជា,ឃ្លេ,ទានព្រៃ,ភ្នំភ្លើង,តាសេក,ត្នួរ.

ឃ.៣.៣ ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិនៅដដែល

ត្រស់,វល្លិប្រេង,ដូងព្រះ,ផ្ដៅល,ស្លាបគុប,តាអើក,បបួយ,សួត,បបុស,ស្វាព្រាម,ត្រជិត,ភ្ញែកព្រាប,អាវក្រពើ,បន្លាយូន,កក់

## ៤. ការធ្វើនេសាទ

### ក. អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន **៣៦៥** នាក់ ស្រី **២០** នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទ នៅក្នុងសហគមន៍មានចំនួន **២០** នាក់ ស្រី **៨** នាក់ ។
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន **២៥០** នាក់ ស្រី **៤០** នាក់

### ខ. ឧបករណ៍នេសាទ

- ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ:

**តារាង ១:**

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ |
|---|---|---|---|---|
| មង | ១ដៃ=៨០ម | ២ដៃ x ៥០នាក់=១០០ដៃ | ប្រវែងចំនួន=៨០០០ម<br>-ក្រឡា=៣.៥សម<br>-ជំរៅ=១.២ម | ពេញ ១ ឆ្នាំ |
| សន្ទូចរនង | ផ្លែ | ៧០ផ្លែ x៣០នាក់=២១០០ផ្លែ | ចំនួន=២១០០ផ្លែ លេខ១១-១៣ | ពេញ ១ ឆ្នាំ |
| លប | គ្រឿង | ៣គ្រឿង x១៥នាក់=៤៥គ្រឿង | ចំនួន=៤៥គ្រឿង<br>-ក្រឡាត្រៀម=៣សម<br>-កំពស់=១.៥ម<br>-មុខកាត់=០.៦ម | មិថុនា-មិនា |
| បបក់ | គ្រឿង | ២០គ្រឿងx២០នាក់=៤០ | ៤០គ្រឿង/១នាក់=១ គ្រឿង | មករា-សីហា |

តារាង ២:

| ប្រភេទទូក កាណូត | ចំនួន (គ្រឿង) | ចំណុះ (ត.ក្រ) | កំលាំងសេះ |
| --- | --- | --- | --- |
| កាណូត | ៥០ | ៥០០-១០០០ គក្រ | ៥-១៥ សេះ |
| ទូកចែវ | ៤០០ | ២០០ គក្រ | គ្មាន |

- ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកនៅក្នុងតំបន់ ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ:

តារាង ៣:

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង |
| --- | --- | --- | --- |
| មង | ១ដៃ=៥០ម | ២ដៃ x ៣០នាក់=៦០ដៃ | ប្រវែងចំនួន=៣០០០ម<br>-ក្រឡា=៣.៥-៥.៥សម<br>-ជំរៅ=១.២ម |
| សន្ទូចរនង | ផ្លែ | ៨០ផ្លែ x២០នាក់=១៦០០ផ្លែ | ចំនួន=១៦០០ផ្លែ លេខ១១-១៣ |

តារាង ៤:

| ប្រភេទទូក កាណូត | ចំនួន(គ្រឿង) | ចំណុះ | កំលាំងសេះ |
| --- | --- | --- | --- |
| ទូកឈើ | ២ | ៥០០-១០០០ គក្រ | ៣-១៥ សេះ |
| ទូកឈើ | ៤០ | ២០០ គក្រ | គ្មាន |

- ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍នេសាទ:

តារាង ៥:

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង |
| --- | --- | --- | --- |
| មង | ១ដៃ=៥០ម | ២ដៃ x ៦០នាក់=១២០ដៃ | ប្រវែងចំនួន=៦០០០ម<br>-ក្រឡា=៣.៥-៥សម<br>-ជំរៅ=១.២ម |
| បង្កៃ | ផ្លែ | ១០០ផ្លែX១០នាក់=១០០០ផ្លែ | ចំនួន=១០០០ផ្លែ លេខ១១-១៣ |
| សន្ទូចរនង | ផ្លែ | ៧០ផ្លែ x៣០នាក់=២១០០ផ្លែ | ចំនួន=២១០០ផ្លែ លេខ១១-១៣ |

តារាង ៦:

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
| --- | --- | --- | --- |
| ទូកម៉ាស៊ីន | ៦០ | ៥០០-១០០០គក្រ | ៣-៧ សេះ |
| ទូកចែវ | ៥០ | ១០០ គក្រ | គ្មាន |

គ. ប៉ាន់ប្រមាណ ផលនេសាទចាប់បានប្រចាំឆ្នាំ

តារាង ៧:

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ (គិតជា គក) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ៣៥៥០ គក្រ | ៦ ៨៦០ គក្រ | ១០ ៤១០ គក្រ |
| ក្តាម ខ្យង | ៣០០០ គក្រ | ១២០០០ គក្រ | ១៥ ០០០ គក្រ |
| កង្កែប និងគីង្គក់ | ៨០ គក្រ | ១៧០ គក្រ | ២៥០ គក្រ |

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ក. ទស្សនៈវិស័យ

សហគមន៍នេសាទ **តរជ្រុំ** មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### ខ. គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបដែលបានលុប ឬកាត់បន្ថយពីនាទីឡូត៍នេសាទ កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទ កន្លែងនេសាទបំរុងទំនាបលិចទឹកក្នុងរដូវដំឡើង នាទីព្រៃលិចទឹក
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍នេសាទ តាមរយៈការអភិវឌ្ឍន៍ចំរុះដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ។

### គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

#### គ.១- ផែនការប្រើប្រាស់ឧបករណ៍នេសាទ:

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម:

តារាង ៨:

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន (នាក់) | |
| បឹងចក.ភក់ | ឧសភា-មីនា | មង | ប្រវែងចំនួន=៦៤០០ម<br>-ក្រឡា=២.៥-៥.៥សម<br>-ជំរៅ=១.២ម | ៨០នាក់ | |
| អន្លង់រាំង | ឧសភា-មីនា | សន្ទូចរនង | ៣០០០ផ្លែលេខ ១១-១៣ | ៦០នាក់ | |
| | ឧសភា-មីនា | លប | ចំនួន=២០គ្រឿង<br>-ក្រឡាត្រៀម=៣សម<br>-កំពស់=១.៥ម<br>-មុខកាត់=0.៦ម | ១០នាក់ | |

## គ.២ ផែនការកែលំអដែននេសាទ

ផែនការកែលំអដែននេសាទត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម:

តារាង ៩:

| ឈ្មោះដែននេសាទ | ទំហំ ហ.ត | ទំហំដែលត្រូវកែលំអ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| បឹងភក់ | ៩ | ប=៥០០ម<br>ទ=២០០ម.ជំរៅ=១ម | ស្តារដោយគ្រឿងចក្រ | ខែមីនា២០០៨ | ខែមេសា ២០០៨ | ២៥០០ដូ |

## គ.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស នឹងត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម:

តារាង ១០:

| ឈ្មោះ/ទីតាំង | ទំហំ (ហ.ត) | ប្រភេទនៃការអភិរក្ស | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| បឹងភក់ | ៦ | ត្រីមេពូជ និងព្រៃជុំវិញ | បោះស្លាក.ដាក់ដែកលួស.បោះបង្គោល.ផ្សព្វផ្សាយ | ខែមករា២០០៨ | ខែមីនា២០០៨ | ៨000 ល្លារ |

| | | | | | | |
|---|---|---|---|---|---|---|
| ព្រៃបឹងភក់ | ២ | ព្រៃលិចទឹក | ផ្សព្វផ្សាយ<br>បោះស្លាកសញ្ញា<br>បោះព្រំប្រទល់<br>និងការពារ | ខែមេសា២០០៨ | ខែកក្កដា២០០៨ | ១៥០០ដុល្លារ |

## គ.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹកត្រូវបានរៀបចំឡើង ដូចមាននៅក្នុងតារាងខាងក្រោម:

**តារាង ១១:**

| ឈ្មោះ/ទីតាំង | ទំហំ (ហ.ត) | ប្រភេទកូនឈើដែលត្រូវដាំ និងការពារ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ១-ដាំព្រៃលិចទឹកមាត់បឹងភក់ | ៥.៥ ហិកតា | រាំង,ចង្កែង ត្រស់ ទានព្រៃ បបួយ | បណ្តុះបណ្តាល ផ្សព្វផ្សាយ | ខែវិច្ឆិកា ២០០៩ | ខែមិថុនា ២០១០ | |
| ២-ថែរក្សា និងរំលោះព្រៃលិចទឹក បឹងវង្វេង បឹងចក ត្រពាំងអន្ទង់រាំង | ៦ ហិកតា | រាញ,ទៀនព្រៃ រាំង,ចង្កែង | ល្បាត បោះផ្លាក | ខែមីនា ២០១០ | ខែមិថុនា ២០១០ | |

## គ-៥ ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការអភិវឌ្ឍន៍វារីវប្បកម្មត្រូវបានរៀបចំឡើងដូចខាងក្រោម:

**តារាង ១២:**

| ប្រភេទវារីវប្បកម្ម | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | ប្រមូលផល |
| ស្រះ៦ម x ៤ម | ៥ | ប្រា,អណ្តែង | ១០០០ក្បាល/ស្រះ | ខែកុម្ភៈ ២០០៩ | ខែសីហា ២០១០ |

## គ-៦ ផែនការចរិកាទ្រទ្រង់សំរាប់អភិវឌ្ឍសហគមន៍

**តារាង ១៣:**

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំ ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ចំណូលសរុប |
|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍ | ផ្សព្វផ្សាយ,ប្រមូល | ខែកុម្ភៈ ២០០៨ | ខែកញ្ញា ២០០៨ | ១៨២.៥០០រៀល |
| ភាគទានប្រចាំឆ្នាំ | ផ្សព្វផ្សាយ,ប្រមូល | ខែមករា ២០០៩ | ខែធ្នូ ២០១០ | ១៨២.៥០០រៀល |

## គ-៧ ផែនការសុខភាព និងអនាម័យ

**តារាង ១៤:**

| ប្រភេទសកម្មភាព | ចំនួនគ្រួសារ | បរិមាណ | ចំនួនថវិកា | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | បញ្ចប់ |
| ធ្វើបង្គន់អនាម័យ | ៣ | ២ បង្គន់ | ១៥០០ ដុល្លារ | ខែឧសភា ២០០៨ | ខែកក្កដា ២០០៩ |
| ផ្តល់ធុងចម្រុះទឹកស្អាត | ១០ | ៥០ធុង | ៣០ ដុល្លារ | ខែមករា ២០០៨ | ខែមករា ២០០៩ |

## គ-៨ ផែនការកសាងក្នុងសហគមន៍នេសាទ

**តារាង ១៥:**

| ប្រភេទសកម្មភាព | បរិមាណ | ចំនួនថវិកា | ខែ/ឆ្នាំ | |
|---|---|---|---|---|
| | | | ចាប់ផ្តើម | បញ្ចប់ |
| ទិញកាណូតស.ន | ១គ្រឿង | ១៣៥០ ដុល្លារ | ខែមេសា ២០០៩ | ខែធ្នូ២០០៩ |
| សង់ស្នាក់ការស.ន | ១ខ្នង | ២៨០០០ ដុល្លារ | ខែមេសា ២០១០ | ខែកក្កដា២០១០ |

## គ-៩ ផែនការទ្រទ្រង់ជីវភាព

**តារាង ១៦:**

| ប្រភេទសកម្មភាព | ចំនួនគ្រួសារ | បរិមាណ | ចំនួនថវិកា | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | បញ្ចប់ |
| មាន់ចិញ្ចឹម | ២០ | ៦០ក្បាល | ២៤០ ដុល្លារ | ខែវិច្ឆិកា ២០០៩ | ខែធ្នូ ២០១០ |
| ទាចិញ្ចឹម | ២០ | ៦០ ក្បាល | ២៤០ ដុល្លារ | ខែវិច្ឆិកា ២០០៩ | ខែធ្នូ ២០១០ |
| ជ្រូក | ១០ | ១០ ក្បាល | ៣០០ ដុល្លារ | ខែវិច្ឆិកា ២០០៩ | ខែធ្នូ ២០១០ |
| គោ | ៥ | ៥ ក្បាល | ១៥០០ ដុល្លារ | ខែវិច្ឆិកា ២០០៩ | ខែធ្នូ ២០១០ |
| ក្របី | ៥ | ៥ ក្បាល | ១៧៥០ ដុល្លារ | ខែវិច្ឆិកា ២០១០ | ខែធ្នូ ២០១០ |

## ឃ. យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំ ដូចខាងក្រោម:

- បង្កើតគណៈកម្មការសម្រាប់អនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៍ផែនការ រួមមាន: សមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ និងសមាជិកសហគមន៍នេសាទដែល មានបទពិសោធន៍ និងចំណេះដឹងល្អ ជាពិសេសអំពីបញ្ហានេសាទ

- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែលទាក់ទងនឹងបច្ចេកទេសជលផលដូចជាៈការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រែក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់
- ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសំរាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ ។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ គរជ្រៃ រយៈពេល ៣ ឆ្នាំ (២០០៨ ដល់ ២០១០)

តារាង ១៧:

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១. ការប្រើប្រាស់ឧបករណ៍នេសាទ | ត្រួតពិនិត្យតាមបឹងចក ភក់ និងអន្លង់រាំង | ជំរុញឱ្យសមាជិកស.នប្រើប្រាស់ឧបករណ៍នេសាទតាមផែនការដែលបានកំណត់បឹងនីមួយៗ | ៨០០ ដុល្លា | -អង្គការក្រៅរដ្ឋាភិបាល<br>-គម្រោងផ្សេងៗរបស់រដ្ឋាភិបាល | ២០០៩ | ២០១០ | |
| ២. ការកែលំអដែននេសាទ | ស្តារបឹងជីកដោយគ្រឿងចក្រ | កន្លែងស្តារនៅក្នុងបឹងភក់ទឹកមិនរីងនៅរដូវប្រាំង | ២៥០០ ដុល្លា | -អង្គការក្រៅរដ្ឋាភិបាល<br>-គម្រោងផ្សេងៗរបស់រដ្ឋាភិបាល | ខែមីនា ២០០៩ | ខែមេសា ២០១០ | |
| ៣. ការកំណត់ និងរៀបចំតំបន់អភិរក្ស | បោះស្លាកសញ្ញា ដាក់ដែកលួស បោះបង្គោល និងផ្សព្វផ្សាយ | ទំហំតំបន់អភិរក្សក្នុងបឹងភក់ចំនួន ៦ ហិកតាបានបង្កើតឡើង | ៣០០០ ដុល្លា | -អង្គការក្រៅរដ្ឋាភិបាល<br>-គម្រោងផ្សេងៗរបស់រដ្ឋាភិបាល | ខែមករា ២០០៩ | ខែមីនា ២០១០ | |
| ៤. ផែនការគ្រប់គ្រងព្រៃលិចទឹក | បោះស្លាកសញ្ញា បោះបង្គោល និង ផ្សព្វផ្សាយ បណ្តុះកូនឈើដាំ និងផ្សព្វផ្សាយ បោះស្លាកសញ្ញា និងល្បាត | ទំហំព្រៃលិចទឹកចំនួន ៦ ហិកតាការពារទុកជាជំរកសម្រាប់ជីវចំរុះគ្រប់ប្រភេទ | ២៧១៥ ដុល្លា | -អង្គការក្រៅរដ្ឋាភិបាល<br>-គម្រោងផ្សេងៗរបស់រដ្ឋាភិបាល | ខែមេសា ២០០៩ | ខែមិថុនា ២០១០ | |
| ៥. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | ផ្តល់កូនត្រីពូជដល់សមាជិកសហគមន៍នេសាទ | សមាជិកសហគមន៍នេសាទនឹងទទួលបានកូនត្រីចំនួន ៥០០០ កូនដាក់ក្នុងស្រះចំនួន៥ | ២០០០ ដុល្លា | -អង្គការក្រៅរដ្ឋាភិបាល<br>-គម្រោងផ្សេងៗរបស់រដ្ឋាភិបាល | ខែមីនា ២០០៩ | ខែសីហា ២០១០ | កូនត្រីប្រា និងអណ្តែង |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៦. ផែនការថវិកាទ្រទ្រង់អភិវឌ្ឍនសហគមន៍ | ប្រមូលប្រាក់ភាគទានពីសមាជិកសហគមន៍នេសាទ និងប្រមូលប្រាក់ភាគទានប្រចាំឆ្នាំ | សមាជិកសហគមន៍នេសាទ និងបង់ប្រាក់គ្រប់ចំនួន | ២៥០ ដុល្លា | -គណៈកម្មការសហគមន៍នេសាទ | ខែមករា ២០០៩ | ខែធ្នូ ២០១០ | |
| ៧. ផែនការសុខភាព និងអនាម័យ | ធ្វើបង្គន់អនាម័យ និងផ្តល់ធុងចម្រោះទឹកស្អាត | កាត់បន្ថយភាពកខ្វក់ និងជំងឺឆ្លងនៅក្នុងភូមិ | ៤០០ ដុល្លា | -គម្រោងរដ្ឋាភិបាល<br>-អង្គការក្រៅរដ្ឋាភិបាល<br>-ថវិកាបដិភាគស.ន | ខែឧសភា ២០០៩ | ខែកក្កដា ២០១០ | |
| ៨. ផែនការកសាងក្នុងស.ន | សង់ស្នាក់ការសហគមន៍ និងទិញកាណូត | ស.ន នឹងមានទីកន្លែងសម្រាប់ប្រជុំពិភាក្សា និង មានកាណូតសម្រាប់ចុះ ធ្វើការងារផ្សេងៗនៅក្នុងសហគមន៍ | ៣៨៥០ ដុល្លា | -គម្រោងរដ្ឋាភិបាល<br>-អង្គការក្រៅរដ្ឋាភិបាល<br>-ថវិកាបដិភាគស.ន | ខែមេសា ២០០៩ | ខែកក្កដា ២០១០ | |
| ៩. ផែនការទ្រទ្រង់ជីវភាពសមាជិកស.ន | ចិញ្ចឹមមាន់ ទា ជ្រូក គោ និងក្របី | សមាជិកសហគមន៍ចំនួន៦០គ្រួសារនឹងអាចរកចំណូលបន្ថែមតាមរយៈការចិញ្ចឹមសត្វ | ៤០៣០ ដុល្លា | -គម្រោងរដ្ឋាភិបាល<br>-អង្គការក្រៅរដ្ឋាភិបាល | ខែវិច្ឆិកា ២០០៩ | ខែធ្នូ ២០១០ | |

| សកម្មភាព | តារាងកម្មវិធីការងារ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ឆ្នាំ ២០០៨ | | | | | | | | | | | | ឆ្នាំ ២០០៩ | | | | | | | | | | | | ឆ្នាំ ២០១០ | | | | | | | | | | | |
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
| ១. ការប្រើប្រាស់ឧបករណ៍នេសាទ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ២. ការកែលំអដែន នេសាទ | | | ■ | ■ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៣. ការកំណត់ និង រៀបចំតំបន់អភិរក្ស | ■ | ■ | ■ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៤. ផែនការគ្រប់គ្រងព្រៃលិចទឹក | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | | |
| ៥. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម តាមស្រះ | | | | | | | | | | | | | | | ■ | ■ | ■ | ■ | ■ | ■ | | | | | | | | | | | | | | | | |
| ៦. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍសហគមន៍ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ៧. ផែនការសុខភាព និងអនាម័យ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | | | | | | | | | | | | | | | | | | |
| ៨. ផែនការកសាងក្នុងសហគមន៍នេសាទ | | | | | | | | | | | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | |
| ៩. ផែនការទ្រទ្រង់សមាជិកសហគមន៍នេសាទ | | | | | | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |

បានឃើញ និងបញ្ជូនមក

លោកនាយខណ្ឌរដ្ឋបាលជលផល.......

នាយសង្កាត់រដ្ឋបាលជលផល...កំពង់ត្រាឡាច

.......ថ្ងៃទី...11...ខែ...10......ឆ្នាំ ២០០8

[signature] ឌី.ថៅ

លេខ :............

បានឃើញ

មេឃុំ...ពោធិ៍

......ថ្ងៃទី...11...ខែ...10.....ឆ្នាំ ២០០8

[signature] ចិន ផាន់ណារ៉ា

លេខ :...497 ភប

ចំបក់...ថ្ងៃទី...11...ខែ...10.....ឆ្នាំ ២០០8

ប្រធានគណៈកម្មការសហគមន៍នេសាទ

[signature] ហ៊ី.ចៅ

លេខ :...02 ភក

បានឃើញ និងឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី..........ខែ.........ឆ្នាំ ២០០

ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

បានឃើញ និងបញ្ជូនមក

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

" ដើម្បីពិនិត្យ និង សម្រេចដោយអនុគ្រោះ"

.......ថ្ងៃទី...27...ខែ...11...ឆ្នាំ ២០០8

នាយអធិការដ្ឋានរដ្ឋបាលជលផល...ដែនទន្លេសាប

[signature] [illegible]

បានឃើញ និងបញ្ជូនមក

លោកនាយអធិការដ្ឋានរដ្ឋបាលជលផល...ដែនទន្លេសាប

.......ថ្ងៃទី...21...ខែ...10...ឆ្នាំ ២០០8

នាយខណ្ឌរដ្ឋបាលជលផល...កំពង់ឆ្នាំង

[signature] [illegible]